ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងខេត្តព្រះសីហនុ

[redacted]ាលក្រមព្រហ្មទណ្ឌលេខ: ៨២-ជ-
ថ្ងៃទី ០៨ ខែ សីហា ឆ្នាំ ២០១៧
ណុំរឿងព្រហ្មទណ្ឌលេខ ១៥៣
ថ្ងៃទី ១៩ ខែ កុម្ភៈ ឆ្នាំ ២០១៧

## តាម នាម ប្រ ជា រា ស្ត្រ ខ្មែ រ
## សាលាដំបូងខេត្តព្រះសីហនុ

បានបើកសវនាការជាសាធារណៈ នៅសាលសវនាការសាលាដំបូងខេត្តព្រះសីហនុ នៅថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ២០១៧ វេលាម៉ោង ៩ និង ០០ នាទីព្រឹក និងប្រកាសសាលក្រមនៅថ្ងៃទី ០៨ ខែ សីហា ឆ្នាំ ២០១៧ វេលាម៉ោង ៩:០០ នាទី ព្រឹក ដែលមានសមាសភាពដូចតទៅ:

**<u>ចៅក្រមជំនុំជម្រះ</u>**

-លោក [redacted] ជាចៅក្រមសាលាដំបូងខេត្តព្រះសីហនុ

**<u>តំណាងអយ្យការ</u>**

-លោក [redacted] ជាព្រះរាជអាជ្ញារងអមសាលាដំបូងខេត្តព្រះសីហនុ

**<u>ក្រឡាបញ្ជីសវនាការ</u>**

-លោក [redacted] ជាក្រឡាបញ្ជីសាលាដំបូងខេត្តព្រះសីហនុ

ដើម្បីជំនុំជម្រះលើសំណុំរឿងព្រហ្មទណ្ឌលេខ: ១៥៣ ចុះថ្ងៃទី ១៩ ខែ កុម្ភៈ ឆ្នាំ ២០១៧ ដែលមានជនជាប់ចោទ:

១-ឈ្មោះ [redacted] ហៅ វ៉ាង ភេទប្រុស អាយុ ២៦ ឆ្នាំ ជនជាតិខ្មែរ មុខរបរ កម្មកររោងចក្រ កើតនៅសង្កាត់លេខ៤ ខណ្ឌមិត្តភាព ក្រុងព្រះសីហនុ មានទីលំនៅមុនពេលឃាត់ខ្លួន នៅភូមិអណ្តូងថ្ម ឃុំអណ្តូងថ្ម ស្រុកព្រៃនប់ ខេត្តព្រះសីហនុ ប្រពន្ធឈ្មោះ ជូវ ស្រស់ មានកូន ០១ នាក់ ឪពុកឈ្មោះ [redacted] (ស) ឈ្មោះ ម្តាយឈ្មោះ [redacted] ប្រវត្តិនៃការផ្តន្ទាទោសព្រហ្មទណ្ឌ "គ្មាន"។

ឃុំខ្លួនតាមដីកាបង្គាប់ឲ្យឃុំខ្លួនលេខ: ៥៧៥ ត.ព.ជ/១៧ ចុះថ្ងៃទី ២០ ខែ កុម្ភៈ ឆ្នាំ ២០១៧។

២-ឈ្មោះ [redacted] ហៅ តូ ភេទប្រុស កើតឆ្នាំ ១៩៩៩ ជនជាតិខ្មែរ មុខរបរ កេតកាត់ កើតនៅភូមិ៤ សង្កាត់លេខ៤ ខណ្ឌមិត្តភាព ក្រុងព្រះសីហនុ មានទីលំនៅមុនពេលឃាត់ខ្លួន នៅភូមិ



Scanned by CamScanner

អណ្តូងថ្ម ឃុំអណ្តូងថ្ម ស្រុកព្រៃនប់ ខេត្តព្រះសីហនុ ប្រពន្ធឈ្មោះ [redacted] មានកូន ០១ នាក់ ឪពុកឈ្មោះ [redacted] ម្តាយឈ្មោះ [redacted] ប្រវត្តិនៃការផ្តន្ទាទោសដោយតុលាការ "គ្មាន"។

ឃុំខ្លួនតាមដីកាបង្គាប់ឲ្យឃុំខ្លួនលេខ: ៥៧៧ ត.ព.ដ/១៧ ចុះថ្ងៃទី ២០ ខែ កុម្ភៈ ឆ្នាំ ២០១៧។

ជាប់ចោទពីបទ: អំពើលួច ប្រព្រឹត្តនៅក្រុម១ ភូមិ៤ សង្កាត់លេខ៤ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ កាលពីថ្ងៃទី ០៨ ខែ កុម្ភៈ ឆ្នាំ ២០១៧ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៣៥៣ និងមាត្រា ៣៥៦ នៃក្រមព្រហ្មទណ្ឌ។

៣-ឈ្មោះ [redacted] ហៅ ដូច ភេទប្រុស អាយុ ២៥ ឆ្នាំ មុខរបរ ជាងម៉ូតូ ជនជាតិខ្មែរ កើតនៅភូមិអណ្តូងថ្ម ឃុំអណ្តូងថ្ម ស្រុកព្រៃនប់ ខេត្តព្រះសីហនុ មានទីលំនៅមុនពេលឃាត់ខ្លួន នៅភូមិអណ្តូងថ្ម ឃុំអណ្តូងថ្ម ស្រុកព្រៃនប់ ខេត្តព្រះសីហនុ ប្រពន្ធឈ្មោះ ម៉ាត់ កល្យាណ មានកូន ០១ នាក់ ឪពុកឈ្មោះ [redacted] ម្តាយឈ្មោះ [redacted] ប្រវត្តិនៃការផ្តន្ទាទោសដោយតុលាការ "គ្មាន"។

ដោយមានលោក [redacted] ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted]

ឃុំខ្លួនតាមដីកាបង្គាប់ឲ្យឃុំខ្លួនលេខ: ៥៧៩ ត.ព.ដ/១៧ ចុះថ្ងៃទី ២០ ខែ កុម្ភៈ ឆ្នាំ ២០១៧។

៤-ឈ្មោះ [redacted] ប្រុស កើតឆ្នាំ ១៩៨៦ ជនជាតិខ្មែរ កើតនៅភូមិវាលមាស ឃុំវាលរេញ ស្រុកព្រៃនប់ ខេត្តព្រះសីហនុ មានទីឡំនៅបច្ចុប្បន្ន នៅភូមិវាលមាស ឃុំវាលរេញ ស្រុកព្រៃនប់ ខេត្តព្រះសីហនុ ឪពុកឈ្មោះ [redacted] ម្តាយឈ្មោះ [redacted]) ប្រវត្តិនៃការផ្តន្ទាទោសដោយតុលាការ "គ្មាន"។ (គេចខ្លួន)

ឃុំខ្លួនតាមដីកាបង្គាប់ឲ្យចាប់ខ្លួនលេខ:៥៣ ត.ព/១៧ ចុះថ្ងៃទី១៨ ខែមេសា ឆ្នាំ ២០១៧។

ជាប់ចោទពីបទ: ទទួលផលចោរកម្ម ប្រព្រឹត្តនៅក្រុម១ ភូមិ៤ សង្កាត់លេខ៤ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ កាលពីថ្ងៃទី ០៨ ខែ កុម្ភៈ ឆ្នាំ ២០១៧ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៣៩៩ និងមាត្រា ៤០០ នៃក្រមព្រហ្មទណ្ឌ។

តាមដីកាបញ្ជូនសំណុំរឿងទៅជំនុំជម្រះលេខ: ១២៥៧ ត.ព/១៧ ចុះថ្ងៃទី ១៦ ខែ ឧសភា ឆ្នាំ ២០១៧ របស់ចៅក្រមស៊ើបសួរនៃសាលាដំបូងខេត្តព្រះសីហនុ។

## អង្គហេតុកើតមានឡើងដូចតទៅ:

កាលពីថ្ងៃទី ០៨ ខែ កុម្ភៈ ឆ្នាំ ២០១៦ ម៉ោង ០៤:០០ នាទីទៀបភ្លឺ ស្ថិតនៅក្រុម០១ ភូមិ៤ សង្កាត់លេខ៤ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ មានករណីអំពើលួចមួយបានកើតឡើង បង្កដោយឈ្មោះ [redacted] និងឈ្មោះ [redacted] បានធ្វើសកម្មភាពលួចម៉ូតូរបស់ជនរងគ្រោះ ឈ្មោះALI UNLU ភេទប្រុស ជនជាតិទួគី បានម៉ូតូម៉ាក អ៊ែប្លែកពណ៌ខ្មៅចំនួន ០១ គ្រឿង។ ក្រោយពេលធ្វើសកម្មភាពលួចម៉ូតូរួចហើយ ជនជាប់ចោទទាំងពីរ ក៏បានយកម៉ូតូទៅលក់ឱ្យឈ្មោះ [redacted] និងឈ្មោះ [redacted]

### នាពេលសវនាការ

-ជនជាប់ចោទឈ្មោះ [redacted] បានឆ្លើយថា៖ខ្លួនធ្លាប់យកម៉ូតូទៅលក់ឱ្យឈ្មោះ [redacted]



Scanned by CamScanner

បានម្តង កាលពីថ្ងៃខែមិនចាំ ហើយម៉ូតូនោះខ្លួនបានលួចគេមកដោយមិនចាំថ្ងៃខែលួចនោះទេ។ ខ្លួនធ្លាប់ទៅលួចម៉ូតូគេជាមួយឈ្មោ[redacted]ានចំនួន ០២ ទៅ ០៣ ដងមកហើយ។ ខ្លួនធ្លាប់យកម៉ូតូដែលលួចពីគេទៅលក់ឱ្យឈ្មោ[redacted]ចំនួន ០៥ ទៅ ០៦ ដងមកហើយ និងលក់ឱ្យឈ្មោ[redacted]២ ទៅ ០៣ ដងមកហើយដែរ។ នៅពេលដែលខ្លួនលក់បានលុយហើយ ខ្លួនយកលុយទាំងអស់នោះទៅលេងល្បែង ជល់មាន់ លេងអាប៉ោងជាដើម។ នាពេលកន្លងមក គឺខ្លួនតែងតែលួចអាវេវ ឆ្លាម និងអាសង់ដោយលួចសរុបបានចំនួន ១៥ ដងមកហើយ។

-ជនជាប់ចោទឈ្មោ[redacted]ានឆ្លើយថា៖ ខ្លួនក៏ធ្លាប់យកម៉ូតូដែលបានលួចពីគេទៅលក់ឱ្យឈ្មោ[redacted]ម្តងដែរ ។ ខ្លួន និងឈ[redacted]និយាយគ្នាថា បើខ្លួនលួចបានហើយ នោះខ្លួននឹងយកទៅលក់ឱ្យឈ្មោះ[redacted]ះ។ ខ្លួនពិតជាបានលួចម៉ូតូគេពិតមែន ដោយទៅជាមួយឈ្មោះ [redacted]ានចំនួន ០២ ដង ហើយខ្លួនក៏យកម៉ូតូដែលលួចបាននេះទៅលក់ឱ្យឈ្មោះ សុខ ចំរើន។ ឈ្មោះ[redacted]តបានដឹងថាម៉ូតូដែលខ្លួន និងឈ្មោះ[redacted]ក់ឱ្យនោះជាម៉ូតូដែលបានមកពី[redacted] ហើយប្រាក់ដែលខ្លួនបានមកពីការលក់ម៉ូតូនេះ គឺខ្លួនយកទៅទិញគ្រឿងញៀនជក់។

-ជនជាប់ចោទឈ្មោះ[redacted]បានឆ្លើយថា ៖ ខ្លួនធ្លាប់ទិញម៉ូតូពីឈ្មោះ [redacted] បានចំនួន ០២ ដង តែឈ្មោះ [redacted]នបានប្រាប់ខ្លួនថាម៉ូតូនេះបានមកពីណានោះទេ ហើយខ្លួនក៏មិនដឹងថាម៉ូតូដែលឈ្មោ[redacted]កមកលក់ឱ្យខ្លួននេះជាម៉ូតូលួចគេដែរ។ នៅរាល់ការទិញលក់ម៉ូតូជាមួយឈ្មោះ[redacted]នះ គឺពុំមានធ្វើលិខិតស្នាមអ្វីឡើយ ពោលគឺទិញដោយនិយាយគ្នាផ្ទាល់មាត់តែប៉ុណ្ណោះ ព្រោះខ្លួនមិនចេះធ្វើលិខិតស្នាមទិញលក់នោះទេ។

-សេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការ៖ ក្រោយពីបានស្តាប់ចម្លើយជនជាប់ចោទឈ្មោះ [redacted]និងឈ្មោះ[redacted]ានឆ្លើយសារភាពថា ពួកខ្លួនពិតជាបានប្រព្រឹត្តសកម្មភាពលួចម៉ូតូរបស់គេពិតមែន។ ដោយឡែកជនជាប់ចោទឈ្មោ[redacted]ានឆ្លើយបដិសេធថា ខ្លួនមិនបានដឹងថាម៉ូតូដែលខ្លួនទិញនោះ គឺជាម៉ូតូដែលបានមកអំពើលួចនោះឡើយ។ ចម្លើយនេះមិនអាចឱ្យតុលាការជឿជាក់បាននោះទេ ព្រោះថាយោងតាមចម្លើយរបស់ឈ្មោះ [redacted]ន ឆ្លើយថា ឈ្មោះ[redacted]ពិតជាដឹងថាម៉ូតូនោះជាម៉ូតូដែលពួកខ្លួនលួចពីគេយកទៅលក់ឱ្យខ្លួន។ មួយវិញទៀតជនជាប់ចោទឈ្មោះ[redacted]ត្រូវបានឈ្មោ[redacted]ប់យកម៉ូតូទៅលក់ឱ្យដែរ ហើយបច្ចុប្បន្នជនជាប់ចោទឈ្មោះ[redacted]នៅតែគេចខ្លួនបាត់ទៅហើយ។ ហេតុដូច្នេះ តំណាងអយ្យការនៅតែប្តឹងសុំលោកចៅក្រមជំនុំជម្រះផ្តន្ទាទោសលើជនជាប់ចោទ [illegible]

-សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] ឈ្មោះ [redacted]ជាជាងម៉ូតូ ដែលមានលទ្ធភាពតិចតួចបំផុតក្នុងរកស៊ីចិញ្ចឹមគ្រួសារ [illegible]



Scanned by CamScanner

ឯការទិញម៉ូតូនេះ ក៏មានតម្លៃតិចតួចផងដែរ ជាពិសេសកូនក្តីខ្លួនក៏មិនដឹងថាម៉ូតូនេះជាម៉ូតូដែលបានមកពីអំពើលួចនោះដែរ។ ហេតុដូច្នេះស្នើសុំលោកចៅក្រមជំនុំជម្រះឱ្យកូនក្តីខ្លួនរួចផុតពីបទចោទប្រកាន់។

-សំដីចុងក្រោយរបស់ជនជាប់ចោទទាំងពីររូបៈ ពួកខ្លួនស្នើសុំតុលាការមេត្តាបន្ធូរបន្ថយទោសដល់រូបខ្លួនផងចុះ។

**ក្រោយពីបាន:**

-ស្តាប់ចម្លើយជនជាប់ចោទ

-ស្តាប់អំណានផ្សេងៗ

-ពិនិត្យភស្តុតាងនានាក្នុងសំណុំរឿង

-ស្តាប់សេចក្តីសន្និដ្ឋានប្តឹងសុំរបស់តំណាងអយ្យការ

-ស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ សុខ ចំរើន

-ស្តាប់សំណូមពរចុងក្រោយរបស់ជនជាប់ចោទ

-ក្រោយពីបានពិនិត្យពិចារណាត្រឹមត្រូវតាមច្បាប់ហើយ

**សាលាដំបូងខេត្តព្រះសីហនុ**

**យល់ឃើញថា**

-ជនជាប់ចោទឈ្មោះ [redacted] និងឈ្មោះ [redacted]បានឆ្លើយសារភាពដោយមានភាពស៊ីសង្វាក់គ្នាថា ពួកខ្លួនពិតជាបានចូលរួមគ្នាប្រព្រឹត្ត អំពើលួចម៉ូតូរបស់គេពិតមែន ហើយក៏បានយកទៅលក់ឱ្យឈ្មោះ[redacted]ងឈ្មោះ[redacted] ដោយលក់ឱ្យឈ្មោះ[redacted]ចំនួន ០៥ ទៅ ០៦ ដងមកហើយ និងលក់ឱ្យឈ្មោះ[redacted]នតែ ០៣ ដងប៉ុណ្ណោះ។ ដោយឡែកជនជាប់ចោទឈ្មោះ[redacted]បានឆ្លើយបដិសេធថា ខ្លួនមិនដឹងថាម៉ូតូដែលខ្លួនទិញនេះជាម៉ូតូរបស់ចោរនោះឡើយ។ ចម្លើយនេះទោះបីជាជនជាប់ចោទបានឆ្លើយបដិសេធយ៉ាងណាក៏ដោយ តែយោងតាមចម្លើយរបស់ឈ្មោះ[redacted]បានឆ្លើយថា ខ្លួន និងឈ្មោះ[redacted]ននិយាយគ្នាមុនថា បើខ្លួនលួចម៉ូតូបាន នោះនឹងយកទៅលក់ឱ្យឈ្មោះ [redacted]។ ជនជាប់ចោទឈ្មោះ [redacted]ានឆ្លើយទៀតថា [redacted]ពិតជាបានដឹងថាម៉ូតូដែលគាត់ទិញនោះជាម៉ូតូដែលបានមកពីលួចគេយ៉ាងពិតប្រាកដ។

-មានភស្តុតាង និងពិរុទ្ធភាពគ្រប់គ្រាន់ដាក់បន្ទុកលើជនជាប់ចោទឈ្មោះ[redacted]ហៅ [redacted]ទប្រុស (មានសាវតាជាតិដូចខាងលើ) និងឈ្មោះ [redacted]ភេទប្រុស (មានសាវតាជាតិដូចខាងលើ) ពីបទ អំពើលួច ប្រព្រឹត្តនៅក្រុម១ ភូមិ៤ សង្កាត់លេខ៤ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ កាលពីថ្ងៃទី ០៨ ខែ កុម្ភៈ ឆ្នាំ ២០១៧ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៣៥៣ និងមាត្រា ៣៥៦ នៃក្រមព្រហ្មទណ្ឌ។



Scanned by CamScanner

-មានភស្តុតាង និងពិរុទ្ធភាពគ្រប់គ្រាន់ដាក់បន្ទុកលើជនជាប់ចោទឈ្មោះ [redacted] ភេទប្រុស (មានសាវតាជាតិដូចខាងលើ) និងឈ្មោះ [redacted]ប្រុស (មានសាវតាជាតិដូចខាងលើ) ពីបទ ទទួលផលចោរកម្ម ប្រព្រឹត្តនៅក្រុម១ ភូមិ៤ សង្កាត់លេខ៤ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ កាលពីថ្ងៃទី ០៨ ខែ កុម្ភៈ ឆ្នាំ ២០១៧ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៣៩៩ និងមាត្រា ៤០០ នៃក្រមព្រហ្មទណ្ឌ។

-ជនជាប់ចោទឈ្មោះ [redacted] ឈ្មោះ [redacted] និងឈ្មោះ [redacted] ជានីតិជនស្ថិតនៅក្នុងនីតិភាពនៃការទទួលខុសត្រូវព្រហ្មទណ្ឌ ហើយបានប្រព្រឹត្តអំពើល្មើសដោយមានចេតនាយល់ដឹងគ្រប់គ្រាន់ចំពោះអំពើ និងព្យសនកម្មដែលកើតឡើងដោយសារការប្រព្រឹត្តអំពើរបស់ខ្លួន។ ប៉ុន្តែជនជាប់ចោទឈ្មោះ [redacted] បានរត់គេចខ្លួន ដែលជាការគេចវេសពីការទទួលខុសត្រូវចំពោះអំពើរបស់ខ្លួនដែលបានប្រព្រឹត្ត។

-ចំពោះវត្ថុដែលចាប់យក គឺមានកំណត់ហេតុចាប់យកដកហូតនៅដំណាក់កាលសមត្ថកិច្ច ប៉ុន្តែមកដល់តំណាងអយ្យការ និងចៅក្រមស៊ើបសួរ ពុំមានកំណត់ហេតុស្តីពីការទទួលវត្ថុតាងឡើយ។ ហេតុដូច្នេះគប្បីតុលាការមិនពិចារណាសម្រេចឡើយ។

-សេចក្តីសន្និដ្ឋាន
របស់តំណាងអយ្យការខាងលើមានលក្ខណៈសមស្របដូចមានក្នុងសំអាងហេតុខាងលើ។

-សេចក្តីសន្និដ្ឋាន របស់មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ មិនមានលក្ខណៈសមស្របដូចក្នុងសំអាងហេតុ និងសំអាងច្បាប់ខាងលើ គប្បីតុលាការមិនលើកយកមកពិចារណា។

-ជនជាប់ចោទឈ្មោះ [redacted] និងឈ្មោះ [redacted] បាននិយាយសំដីចុងក្រោយ សំណូមពរឱ្យតុលាការបន្ធូរបន្ថយទោសដល់ខ្លួនផង។

## ហេតុដូច្នេះ សាលាដំបូងខេត្តព្រះសីហនុ

## វិនិច្ឆ័យ សេចក្តី

**១- ផ្តន្ទាទោស:**

ក-ឈ្មោះ [redacted] ភេទប្រុស អាយុ ២៦ ឆ្នាំ ជនជាតិខ្មែរ (មានសាវតាជាតិដូចខាងលើ) ដាក់ពន្ធនាគារកំណត់រយៈពេល ០១ (មួយ) ឆ្នាំ និង ០៦ (ប្រាំមួយ) ខែ។

ខ-ឈ្មោះ [redacted] ភេទប្រុស កើតឆ្នាំ ១៩៩៩ ជនជាតិខ្មែរ (មានសាវតាជាតិដូចខាងលើ) ដាក់ពន្ធនាគារកំណត់រយៈពេល ០១ (មួយ) ឆ្នាំ និង ០៦ (ប្រាំមួយ) ខែ។

ពីបទៈ អំពើលួច ប្រព្រឹត្តនៅក្រុម១ ភូមិ៤ សង្កាត់លេខ៤ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ កាលពីថ្ងៃទី ០៨ ខែ កុម្ភៈ ឆ្នាំ ២០១៧ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៣៥៣ និងមាត្រា ៣៥៦ នៃក្រមព្រហ្មទណ្ឌ។

គ-ឈ្មោះ [redacted] ភេទប្រុស អាយុ ២៥ ឆ្នាំ ជនជាតិខ្មែរ (មានសាវតាជាតិដូចខាងលើ) ដាក់ពន្ធនាគារកំណត់រយៈពេល ០២ (ពីរ) ឆ្នាំ តែទោសនេះត្រូវអនុវត្តក្នុងពន្ធនាគារកំណត់រយៈពេល



Scanned by CamScanner

០១ (មួយ) ឆ្នាំ ទោសដែលនៅសល់ត្រូវព្យួរការអនុវត្តចម្មតា។

ឃ-ឈ្មោះ [redacted] ភេទប្រុស កើតឆ្នាំ ១៩៨៦ ជនជាតិខ្មែរ (មានសារពាជាតិដូចខាងលើ) ដាក់ពន្ធនាគារកំណត់រយៈពេល ០២ (ពីរ) ឆ្នាំ។

ពីបទ ទទួលផលចោរកម្ម ប្រព្រឹត្តនៅក្រុម១ ភូមិ៤ សង្កាត់លេខ៤ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ កាលពីថ្ងៃទី ០៨ ខែ កុម្ភៈ ឆ្នាំ ២០១៧ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៣៩៩ និងមាត្រា ៤០០ នៃក្រមព្រហ្មទណ្ឌ។

២-សាលក្រមនេះជំនុំជម្រះ និងប្រកាសជាសាធារណៈ ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] ឈ្មោះ [redacted] ហៅ [redacted] និងចំពោះមុខមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] ដោយកំបាំងមុខជនជាប់ចោទឈ្មោះ [redacted]

ទុកសិទ្ធិឲ្យប្តឹងទាស់ និងប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់។

**ក្រឡាបញ្ជី**

**ហត្ថលេខា និងត្រា [redacted]**

**ចៅក្រមជំនុំជម្រះ**

**ហត្ថលេខា និង [redacted]**

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម

ខេត្តព្រះសីហនុ ថ្ងៃទី០៤ ខែកញ្ញា ឆ្នាំ ២០១៧

ក្រឡាបញ្ជី

[redacted]

បានឃើញ

ចៅក្រមជំនុំជម្រះ

[redacted]



Scanned by CamScanner